# <u>សេចក្តីថ្លែងការណ៍បិទបញ្ចប់បេសកកម្ម</u>

<u>សេចក្តីថ្លែងការណ៍ដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា</u>
<u>អ្នកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត</u>
ភ្នំពេញ ១៩ តុលា ២០១៦

**ត្រួតពិនិត្យមុនបញ្ជូនចេញ**

***សេចក្តីផ្តើម***

ឥឡូវនេះខ្ញុំបានបិទបញ្ចប់បេសកកម្មលើកទីបីរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជាហើយ។ ការរកឃើញ និងអនុសាសន៍របស់ខ្ញុំនឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍ដែលខ្ញុំនឹងសរសេរបញ្ចប់ក្នុង ខែឧសភា ឆ្នាំ ២០១៧ សម្រាប់ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សពិនិត្យពិចារណានៅក្នុងខែកញ្ញាឆ្នាំ២០១៧។ នៅចុងខែមុន ខ្ញុំបាននិយាយដល់របាយការណ៍ស្តួលលើកទីមួយរបស់ខ្ញុំដែលបានដាក់ជូនក្រុមប្រឹក្សា។ ដោយសារថា របាយការណ៍នោះត្រូវបានបញ្ចូនក្នុងខែឧសភា ឆ្នាំ២០១៦ ដូច្នេះខ្ញុំអាចធ្វើបច្ចុប្បន្នភាពដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អំពីស្ថានការណ៍វិវឌ្ឍ តាំងពីខែ មិថុនា មក។ មតិរបស់ខ្ញុំដែលបានលើកឡើងក្នុងរបាយការណ៍ នោះនៅតែបន្តលើកឡើងម្តងទៀតនៅថ្ងៃនេះ។

ខ្ញុំសូមអំណរគុណដល់រដ្ឋាភិបាលដែលបានអញ្ជើញខ្ញុំមកធ្វើទស្សនកិច្ចនេះ និងឆន្ទៈរបស់រដ្ឋមន្ត្រីជាច្រើនចង់ជួបជាមួយខ្ញុំ និងពិភាក្សាដោយត្រង់ៗអំពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេស។ ខ្ញុំសូមអរគុណផងដែរ ដល់បុគ្គលិកការិយាល័យ OHCHR នៅកម្ពុជា និងនៅក្រុងហ្សឺណែវ ចំពោះកិច្ចខិតខំប្រឹងប្រែងមិនខ្លាច នឿយហត់របស់ពួកគេ គាំទ្រដល់ដំណើរបេសកកម្មនេះ។ លើសពីនេះទៀតខ្ញុំសូមសម្តែងនូវការកោត សរសើរដល់ដៃគូសន្ទនាទាំងអស់ ដែលមានឆន្ទៈចង់ជួបជាមួយខ្ញុំ និងចែករំលែកបទពិសោធន៍ ក្តីសង្ឃឹម និងកង្វល់របស់ពួកគេ។

ក្នុងដំណើរទស្សនកិច្ចនេះខ្ញុំបានមានឯកសិទ្ធិជួបជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ដែលរួមមាន៖ ឯកឧត្តមប្រាក់សុខុន ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមអង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តមហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង

យុវនីតិសម្បទា និងឯកឧត្តម កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ ខ្ញុំបានជួបផងដែរ ជាមួយប្រធានស្តីទីគណបក្សសង្គ្រោះជាតិ ឯកឧត្តម កឹម សុខា ។

ខ្ញុំសូមសម្តែងកត្តញូតាដល់សមាជិកនៃប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា សហគមន៍ការទូត និងតំណាងតួអង្គសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត រាប់ទាំងវិស័យឯកជនផងដែរ ដែលបានចំណាយពេលវេលាចែករំលែកការយល់ដឹង និងព័ត៌មានជាមួយខ្ញុំ។ ម្យ៉ាងវិញទៀតខ្ញុំបានទៅទស្សនាតាមមូលដ្ឋានផ្សេងៗក្នុងរាជធានីភ្នំពេញនិងនៅខេត្តកំពង់ស្ពឺ ហើយបានជួបជាមួយអាជ្ញាធរក្រុង និងអាជ្ញាធរខេត្ត និងបានជួបជាមួយសមាជិកក្រុមភាគតិចជាតិពន្ធុ និងជនជាតិដើមភាគតិចព្រមទាំងសហគមន៍ដទៃផ្សេងទៀត។

មានព្រឹត្តិការណ៍ជាច្រើនត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកខួបលើកទីម្ភៃប្រាំនៃការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ កិច្ចព្រមព្រៀងទាំងនេះបានរៀបចំបង្កើតគ្រឹះសម្រាប់កម្ពុជាសព្វថ្ងៃនេះ ជារដ្ឋមួយដែលបានកសាងឡើងផ្អែកលើសន្តិភាព និងស្ថិរភាពរឹងមាំ ក្លាយជាសមាជិក សកម្មរបស់អាស៊ាន អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត។ ផ្តើមចេញពីកិច្ចព្រមព្រៀងនេះ ការទទួលស្គាល់បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ បានក្លាយជាផ្នែកសំខាន់ចាំបាច់នៃអភិបាលកិច្ចកម្ពុជា។ មាត្រា៣នៃកិច្ចព្រមព្រៀងនេះដែលពាក់ព័ន្ធនឹង អធិបតេយ្យភាពឯករាជ បូរណភាព និងភាពមិនអាចរំលោភ បាននៃដែនដីអព្យាក្រឹតភាពនិងឯកភាពជាតិរបស់ម្ពុជា ប្រកាសថា៖ ″មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា ត្រូវទទួលបានសិទ្ធិ និងសេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង លិខិតុបករណសិទ្ធិមនុស្សពាក់ព័ន្ធដទៃទៀត″។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ពង្រឹងការប្តេជ្ញាចិត្តនេះចំពោះ សិទ្ធិមនុស្ស ដែលជាក់ស្តែងកម្ពុជាបានស្ម័គ្រចិត្តទទួលយកសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗជាច្រើន។ ការគោរពសិទ្ធិមនុស្សគឺជា បញ្ហាកង្វល់អន្តរជាតិ។ ប្រវត្តិសាស្រ្តកម្ពុជា បានបង្ហាញពីវិបាកនៃសោកនាដកម្ម ទៅលើសិទ្ធិមនុស្សដោយសារតែសិទ្ធិមនុស្សមិនត្រូវបានគោរពឲ្យបានគ្រប់គ្រាន់ និងការពារឲ្យបានមុតមាំ។ កម្ពុជាមិនត្រូវវិលត្រឡប់ទៅស្ថានភាពនៃសង្គ្រាម និងជម្លោះដែលនាំឲ្យបាត់បង់ជីវិតមនុស្សច្រើនក្រៃលែង ការធ្វើឲ្យអន្តរាយដល់ការចិញ្ចឹមជីវិត និងការប៉ះទង្គិចផ្លូវចិត្ត ការដកហូតកម្មសិទ្ធិ និងការធ្វើឲ្យប្រជាពលរដ្ឋ ជាច្រើននៃប្រទេសនេះត្រូវធ្វើចំណាកស្រុក។ ការគោរពសិទ្ធិមនុស្ស គឺជាផ្នែកសំខាន់ចាំបាច់នៃការធានា សន្តិភាពយូរអង្វែង។ សិទ្ធិមនុស្សមិនគំរាមកំហែងដល់សន្តិសុខជាតិទេ ហើយការឃ្លាំមើលសិទ្ធិមនុស្ស ទៀតសោធក៏មិនគំរាមកំហែងដល់អធិបតេយ្យភាពដែរ។ ខ្ញុំមានសេចក្តីរីករាយ ដោយការយល់ដឹងរួម របស់យើង អំពីសិទ្ធិមនុស្ស និងអធិបតេយ្យភាពជាតិ។ ខ្ញុំទទួលបានការលើកទឹកចិត្តជាខ្លាំងដោយសារថា រដ្ឋមន្រ្តីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ យល់ស្របថា ការគោរពអធិបតេយ្យភាពជាតិ និងការគោរពសិទ្ធិមនុស្សត្រូវដើរទន្ទឹមគ្នា។

នៅក្នុងជំនួបប្រជុំរបស់ខ្ញុំជាមួយរដ្ឋមន្រ្តីនានានៃរដ្ឋាភិបាលខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងអំពីឆន្ទៈរបស់ពួកគេដើម្បីធ្វើការលើវិធានការកែលម្អស្ថានភាពសិទ្ធិមនុស្សសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ ក្រសួងជាច្រើន នាបច្ចុប្បន្ននេះបាននិងកំពុងធ្វើការលើការវិភាគអំពីគោលដៅនិងសូចនាករសម្រាប់វាស់ស្ទង់ការរីកចំរើននៃ

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការពង្រឹងការប្រមូលទិន្នន័យដែលអាចជឿទុកចិត្តនឹងអាចឲ្យ ការវាស់ស្ទង់អំពីការរីកចម្រើននេះបានកាន់តែច្បាស់ថែមទៀត។ ខ្ញុំបានដឹងអំពីការងារលើកកំពស់សិទ្ធិ ជនពិការ ការការពារកុមារ (ជាអាទិ៍ ច្បាប់យុត្តិធម៌អនីតិជនច្បាប់សុំកូនក្នុងប្រទេស) ការពារសហគមន៍ ជនជាតិដើមភាគតិចនិងក្រុមជនភាគតិចជាតិពន្ធុដទៃផ្សេងទៀតនិងពង្រឹងការការពារសិទ្ធិស្រ្តី។ កម្ពុជាបាន បង្កើនផងដែរនូវភាពជាតំណាងរបស់ខ្លួននៅកីឡាប៉ារ៉ាអូឡាំពិកលើកទី៣១។ ទាក់ទងនឹងសិទ្ធិស្រ្តីវិញ ខ្ញុំទទួលបានការលើកទឹកដោយដឹងពីកិច្ចខិតខំប្រឹងប្រែង ដែលបាននិងកំពុងធ្វើដើម្បីបញ្ជ្រាបយេនឌ័រ និង ការងារយេនឌ័រនៅតាមបណ្តាក្រសួង-ស្ថាប័ននានា។ **ខ្ញុំផ្តល់អនុសាសន៍យ៉ាងមុតមាំដល់រដ្ឋាភិបាល សូមឲ្យអនុម័តវិធីសាស្ត្រ ឬ អភិក្រម ដែលមានការរួមបញ្ចូលពហុភ្នាក់ងារ និងអន្តរក្រសួង ដើម្បី ជម្រុញវឌ្ឍនភាពសិទ្ធិសេដ្ឋកិច្ចនិងសង្គមកិច្ច។ ជាពិសេសជនពិការស្រ្តី សិទ្ធិជនជាតិដើមភាគតិច និងសិទ្ធិក្រុមជនភាគតិចជាតិពន្ធុ ត្រូវតែមានភាពជាតំណាងមិនត្រឹមតែជាកម្មវត្ថុនៃការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែក៏ជា អ្នកចូលរួមចំណែកនិងជាអ្នកដឹកនាំដ៏សកម្មផងដែរ។**

ខ្ញុំមានការខកចិត្តខ្លះដែរ ដែលរដ្ឋាភិបាលមានការយឺតយ៉ាវខ្លាំង ក្នុងការធ្វើរបាយការណ៍ទៅកាន់ស្ថាប័ន សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ។ ការចូលរួមជាមួយដំណើរការឃ្លាំមើលអន្តរជាតិ ដែលកម្ពុជាបាន ទទួលយកគឺជា សូចនាករមួយដ៏សំខាន់ បង្ហាញថាកម្ពុជា មានឆន្ទៈធ្វើឲ្យប្រសើរឡើងនូវស្ថានភាព សិទ្ធិមនុស្ស។ ការិយាល័យOHCHR បានយល់ព្រមតាមសំណើរបស់គណៈកម្មាធិការនេះ ដើម្បីផ្តល់ការ បណ្តុះបណ្តាលបច្ចេកទេសធ្វើរបាយការណ៍ទាំងនេះដែលអាចជួយពង្រឹងសមត្ថភាពធ្វើរបាយការណ៍បាន។ **ខ្ញុំផ្តល់អនុសាសន៍ដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាសូមឲ្យសម្របសម្រួលជាមួយក្រសួង និង ក្រុមប្រឹក្សាផ្សេងៗទៀតនិងរៀបចំកាលវិភាគដ៏ទូលំទូលាយមួយសម្រាប់ការធ្វើរបាយការណ៍ស្តីពីសន្ធិសញ្ញា សិទ្ធិមនុស្សទាំងអស់។**

*ក្រុមងាយរងគ្រោះ*

ការមានកង្វល់ជាខ្លាំងចំពោះទុក្ខលំបាករបស់ក្រុមមនុស្សងាយរងគ្រោះជាច្រើនដែលខ្ញុំបានជួបនៅក្នុងរយៈពេលទស្សនៈកិច្ចលើកនេះ។ ដូចបានកត់សំគាល់ខាងដើម មាត្រា៣១ នៃរដ្ឋធម្មនុញ្ញថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ដោយហេតុថារាជរដ្ឋាភិបាលកំពុងធ្វើការឈានទៅរៀបចំផ្តល់ការឆ្លើយតបចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ដែលសំខាន់មិនគឺទុកនរណាម្នាក់ចោលឡើយ។ ដូច្នេះខ្ញុំកំពុងពិនិត្យស្ថានភាពក្រុមជនមួយចំនួនពាក់ព័ន្ធនឹងបញ្ហានោះ។

*ក្រុមជនភាគតិចជាតិពន្ធុនិងជនជាតិដើមភាគតិច*

ក្រុមជនភាគតិចជាតិពន្ធុមានសិទ្ធិទទួលបានការការពារដូចមានចែងក្នុងមាត្រា២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ សហគមន៍ចាមនៅទីក្រុង ខ្ញុំរីករាយដោយដឹងថា ជាទូទៅពួកគេត្រូវបានធ្វើសមាហរណកម្មបានល្អទៅក្នុងសង្គមខ្មែរ និងមិនមានអារម្មណ៍ថា សាសនា ឬជាតិពន្ធុរបស់ខ្លួន រងការប៉ះពាល់ដោយការប្រព្រឹត្តចំពោះពួកគេឡើយ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍ចាមក្រីក្រ ជួបប្រទះបញ្ហាប្រឈមដូចគ្នានឹងសហគមន៍ខ្មែរក្រីក្រដទៃទៀតដែរ នៅរាប់ទាំងភាពងាយរងគ្រោះចំពោះសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមកិច្ចរបស់ពួកគេ ដូចជា លទ្ធភាពទទួលបានទឹកស្អាតនិងអនាម័យ ហើយនិងកិច្ចគាំពារសុខភាព។ ចំណុចវិជ្ជមានមួយគឺ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាបានប្រាប់ខ្ញុំពីប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនមូស្លីមជាង១៤០០នាក់ បច្ចុប្បន្ន ត្រូវបានគាំទ្រដោយក្រសួងនេះ។

ផ្ទុយពីនេះ សហគមន៍ជនជាតិវៀតណាមនិងខ្មែរក្រោមមួយចំនួនដែលបានរស់នៅលើទឹកដីកម្ពុជាជាច្រើនជំនាន់ហើយនោះ ទោះបីជាត្រូវបានជន្លៀសចេញពេលជម្លោះប្រដាប់អាវុធក្តី ពួកគេទំនងជាជួបប្រទះបញ្ហាប្រឈមមួយចំនួនខាងការចុះបញ្ជីកំណើតនិងអត្តសញ្ញាណប័ណ្ណ ដែលប៉ះពាល់លើសិទ្ធិដទៃទៀតជាច្រើន។ ខ្ញុំបានចាប់អារម្មណ៍ទៅលើផែនការជាតិយុទ្ធសាស្ត្រអត្តសញ្ញាណកម្ម ហើយសង្ឃឹមថា ការនេះអាចធានាថា កុមារនៅកម្ពុជាទាំងអស់ត្រូវបានចុះបញ្ជីកំណើតនិងអ្នកដែលធ្លាប់មានប្រវត្តិរស់នៅក្នុងប្រទេសនេះ អាចទទួលបានអត្តសញ្ញាណប័ណ្ណផងដែរ។ កុមារគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិនិងការចុះបញ្ជីកំណើត។ ខ្ញុំមានកង្វល់ថាមនុស្សមួយចំនួន ដែលរស់នៅទីនេះគឺគ្មានសញ្ជាតិឬប្រឈមនិងក្លាយទៅជាអ្នកគ្មានសញ្ជាតិ។ បញ្ហានេះទំនងជាការចំអកមួយ នៅខណៈពេលដែលកម្ពុជាបានផ្តល់ទីកន្លែងសម្រាប់ជាទីតាំងលំនៅថ្មីរបស់ជនភៀសខ្លួននៅណាវរុ។ **ខ្ញុំសូមផ្តល់អនុសាសថា រាជរដ្ឋាភិបាលត្រូវគោរពរដ្ឋធម្មនុញ្ញនិងច្បាប់ជាតិនិងអនុសញ្ញាអន្តរជាតិនានាដែលរាជរដ្ឋាភិបាលបានសច្ចាប័នពាក់ព័ន្ធនឹងបញ្ហាសញ្ជាតិ ភាពជាពលរដ្ឋនិងរួចផុតពីការរើសអើង។ ខ្ញុំក៏សូមផ្តល់អនុសាសផងដែរថារាជរដ្ឋាភិបាល ចាត់វិធានការ ការពារនិងបញ្ចប់បញ្ហាជនគ្មានសញ្ជាតិនៅកម្ពុជា។**

*រដ្ឋាភិបាល*

ជនជាតិដើមភាគតិច នៅបន្តជួបប្រទះបញ្ហាប្រឈមជាច្រើន ជាពិសេសបំផុតគឺបញ្ហាដីធ្លី។ សម្បទានដីហើយគម្រោងអភិវឌ្ឍន៍ ជារឿយៗ អាចផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរទៅលើការចិញ្ចឹមជីវិតតាមបែបប្រពៃណី និងប្រពៃណីវប្បធម៌។ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៍ប្រើពេលវេលាយូរ ចំណាយច្រើន និងមានលក្ខណៈស្មុគស្មាញ។ ក្នុងបេសកម្មនេះ ខ្ញុំបានជួបជាមួយតំណាងមកពីសហគមន៍ជនជាតិដើមភាគតិចស្ទួយ ហើយបានរកឃើញនូវបញ្ហាបន្ថែមទៀតលេចចេញមក នៅពេលដែលសមាជិកខ្លះៗនៃសហគមន៍ជនជាតិដើមភាគតិចនោះ ចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីឯកជនដោយជោគជ័យ ក្រោមបទបញ្ជា ០១ ទន្ទឹមនេះ សមាជិកផ្សេងៗទៀតក្នុងសហគមន៍ កំពុងស្វែងរកប័ណ្ណកម្មសិទ្ធិដីសហគមន៍ដែលបានទាមទារលើតំបន់ដីដែលត្រូវបានកាត់បន្ថយ។ សំគាល់ពីចំណុចវិជ្ជមានមួយទៀត ខ្ញុំយល់ថា ការអប់រំពីរភាសានៅតែកំពុងត្រូវបានដាក់ឲ្យអនុវត្ត។ ខ្ញុំផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល ឥឡូវនេះ សូមធ្វើឲ្យដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៍

ឲ្យមានលក្ខណៈសាមញ្ញ ដោយកាត់បន្ថយជំហានមួយចំនួនដែលបានតម្រូវ។ ខ្ញុំស្នើសុំផងដែរដល់រដ្ឋាភិបាលឲ្យពិនិត្យឡើងវិញនូវច្បាប់និងគោលនយោបាយដែលមានស្រាប់ ដើម្បីធានាឲ្យមានការបំពេញទៅតាមសេចក្តីប្រកាសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច និងធានាឲ្យមានការផ្សព្វផ្សាយ និងការអនុវត្តន៍នៅកំរិតមូលដ្ឋាន។ នេះគួរតែជួយធានាការពារផងដែរនូវសំលេងជនជាតិដើមភាគតិចក្នុងយុទ្ធសាស្រ្ត និងគោលនយោបាយជាតិនៅពេលអនាគត។

## *អំពីបញ្ហាជនរស់នៅតាមដងផ្លូវ*

ជនដែលរស់នៅ ធ្វើការ ឬជនដែលពឹងផ្អែកការរស់នៅនៅតាមដងផ្លូវ គឺជាជនងាយរងគ្រោះយ៉ាងខ្លាំង។ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលសំចត (ដែលពីមុនគេស្គាល់ថាមជ្ឈមណ្ឌលព្រៃស្ពឺ) ដើម្បីវាយតម្លៃស្ថានភាពរស់នៅ និងការប្រព្រឹត្តទៅលើជនទាំងនោះដែលគេបានចាប់ប្រមូល និងបញ្ជូន ទៅកាន់មជ្ឈមណ្ឌលនេះ។ វាមិនអាចទទួលយកបានទេចំពោះការចាប់ប្រមូលជនទាំងនោះពីតាមដងផ្លូវ។

ខណៈដែលរដ្ឋមន្រ្តីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានពន្យល់អំពីភាពប្រសើរ ដែលត្រូវបាន ធ្វើឡើងចំពោះមជ្ឈមណ្ឌលនេះ តាមការពិតជាក់ស្តែងគឺថា ការធ្វើឲ្យប្រសើរឡើងឲ្យបានកាន់តែទូលំទូលាយ និងខ្លាំងក្លាបន្ថែមទៀត ត្រូវតែធ្វើជាចាំបាច់។ ខ្ញុំមានកង្វល់ចំពោះចំនួនមនុស្សយ៉ាងច្រើនដែលត្រូវបានដាក់នៅក្នុង បន្ទប់ដែលគ្មានខ្យល់អាកាសគ្រប់គ្រាន់ និងទឹក និងសម្ភារៈអនាម័យដ៏មានកម្រិត។ ទោះបីជាមានការអះអាងថា អ្នកដែលត្រូវបានគេចាប់ប្រមូល និងនាំយកទៅកាន់មជ្ឈមណ្ឌលនេះ ត្រូវតែនៅទីនោះរយៈមួយសប្តាហ៍ ដើម្បីឲ្យ គ្រួសាររបស់ពួកគេចាត់ចែងមកទទួលយកពួកគេទៅវិញក៏ដោយ ក៏មនុស្សភាគច្រើនដែលខ្ញុំបានជួប បានជាប់នៅ មជ្ឈមណ្ឌលនោះអស់រយៈពេលយ៉ាងយូរ និងគ្មានពេលកំណត់ច្បាស់លាស់ឡើយ ហើយត្រូវបានគេឃុំឃាំង ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។ ទង្វើនេះ គឺមិនស្របទៅនឹងអត្ថន័យនៃពាក្យ "សំចត" ឬស្របតាមច្បាប់ឡើយ។ អ្នកជាប់ឃុំជាច្រើន មានបញ្ហាសុខភាព រាប់បញ្ចូលទាំងជំងឺផ្លូវចិត្ត អ្នករស់នៅជាមួយមេរោគ/ជំងឺអេដស៍ និងអ្នកញៀន/ប្រើប្រាស់ថ្នាំញៀន។ អ្នកជាប់ឃុំជាច្រើនបានអះអាងថា ពួកគេមិនអាចទំនាក់ទំនងជាមួយកូន និងក្រុមគ្រួសារនៅខាងក្រៅឡើយ ហើយការគាំពារផ្នែកវេជ្ជសាស្រ្តប្រកបដោយវិជ្ជាជីវៈសមស្រប បច្ចុប្បន្ននេះ ក៏មិនមានដែរ។ ខ្ញុំយល់ថា ការឆ្លើយតបឲ្យបានគ្រប់ជ្រុងជ្រោយដែលមានការសម្របសម្រួលពីអន្តរក្រសួង និង ពហុភ្នាក់ងារ ត្រូវតែមានជាចាំបាច់ និងត្រូវមានធនធានគ្រប់គ្រាន់ ដើម្បីជួយបន្ធូរបន្ថយស្ថានភាពនេះ ហើយខ្ញុំ សូមស្វាគមន៍ចំពោះការអះអាងជាថ្មីម្តងទៀតថា សិទ្ធិចេញចូលមជ្ឈមណ្ឌលនេះម្ភៃបួនម៉ោងនឹងបន្តផ្តល់ជូនភ្នាក់ងារ អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។ **មជ្ឈមណ្ឌលដ៏ត្រឹមត្រូវមួយដែលផ្តល់ការថែទាំ និងផ្តល់សេវា និងជំនួយចាំបាច់ផ្សេងៗដល់ជនរស់នៅតាមដងផ្លូវ គួរតែត្រូវបានកំណត់ជាអាទិភាព ហើយខ្ញុំផ្តល់អនុសាសន៍ដ៏មុតមាំថា វិធានការជាបន្ទាន់ត្រូវតែចាត់ឡើងដោយរាជរដ្ឋាភិបាល ដើម្បីអនុវត្តតាម អនុសាសន៍ទាំងឡាយនៃសន្និសិទ្ធថ្នាក់ជាតិស្តីពី ជនរស់នៅតាមដងផ្លូវ ដែលរៀបចំធ្វើឡើងនៅទីក្រុងភ្នំពេញកាលពីខែធ្នូ កន្លងទៅ។**

បញ្ហាពាក់ព័ន្ធមួយទៀត ខ្ញុំបានដឹងថា មានមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនជាច្រើនសំរាប់អ្នកញៀនថ្នាំញៀន និងមជ្ឈមណ្ឌលមួយត្រូវបានគ្រោងបង្កើតឡើងនៅខេត្តកណ្តាលសំរាប់អ្នកពិការផ្នែកផ្លូវចិត្តផងដែរ។ ខ្ញុំសង្ឃឹមថា នឹងមានការឆ្លើយតបឲ្យបានគ្រប់ជ្រុងជ្រោយក្នុងការដោះស្រាយសេចក្តីត្រូវការជាក់ស្តែង ដើម្បីឲ្យពួកគេទទួលបាន ការគាំទ្រ និងអាចទទួលបានការស្តារនីតិសម្បទាចូលទៅក្នុងសហគមន៍វិញប្រកបដោយជោគជ័យតាមដែលអាច ធ្វើបាន។

*នីតិរដ្ឋ និងយុត្តិធម៌*

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បញ្ជាក់យ៉ាងច្បាស់ថា រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស និងថាឯករាជ្យភាពរបស់ប្រព័ន្ធតុលាការនឹងត្រូវបានពង្រឹងដើម្បីអនុវត្តសិទ្ធិទាំងនេះ។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជា ណាចក្រកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់លាស់អំពី ការទទួលយកការគោរពសិទ្ធិមនុស្ស និងធានាថាច្បាប់ត្រូវ បានអនុវត្តដោយគ្មានការរើសអើងអ្វីឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានឧទាហរណ៍ជាច្រើនដែលច្បាប់ត្រូវ បានមើលឃើញថាកំពុងអនុវត្តដោយមានភាពរើសអើង ឬ ដោយហេតុផលនយោបាយ។ ពាក់ព័ន្ធទៅនឹងសំណុំរឿងក្តី របស់មន្ត្រីអង្គការអាដហុកចំនួន ៥រូប ដែលកំពុងត្រូវបានឃុំខ្លួន ខ្ញុំបានលើកឡើងនៅក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់ អង្គការសហប្រជាជាតិថា ការចោទប្រកាន់ប្រឆាំងនឹងពួកគាត់ត្រូវតែមានការបង្ហាញភស្តុតាង ឬក៏ពួកគាត់គួរតែត្រូវបាន ដោះលែងភ្លាម ដោយត្រូវបិទសំណុំរឿងនោះ។

ច្បាប់កម្ពុជាជាច្រើនត្រូវបានព្រាងឡើងដោយមានការសហការជាមួយប្រទេសម្ចាស់ជំនួយនិងក្រុមអ្នកជំនាញអន្តរជាតិ ផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ជាលទ្ធផលច្បាប់នេះជាច្បាប់របស់កម្ពុជា។ វាសម្រាប់រដ្ឋាភិបាលកម្ពុជា ក្នុងការធានាថា ច្បាប់ទាំងនោះត្រូវបានអនុវត្តទៅតាមរបៀបមួយដែលស្របតាមបទដ្ឋានសិទ្ធិមនុស្សដែលបានផ្តល់ សច្ចាប័ន។ ឧទាហរណ៍មួយដែលទាមទារឲ្យមានការបញ្ជាក់បន្ថែម និងមានសារៈសំខាន់នោះគឺច្បាប់ស្តីពីភ័ស្តុតាង។ មាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌ បានយោងទៅលើលក្ខខណ្ឌតម្រូវដោយច្បាប់នៃការបង្ហាញភស្តុតាង ឧទាហរណ៍មាត្រា ១១៨, មាត្រា ១២៧ និងមាត្រា ៣២១។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាមានការលេចឡើងថា ចៅក្រមផ្សេងៗគ្នា បានអនុវត្តខុសៗគ្នានូវបទដ្ឋានបង្ហាញភស្តុតាង។ បុគ្គលគ្រប់រូបដែលរងការចោទប្រកាន់បទល្មើស ព្រហ្មទណ្ឌ មានសិទ្ធដឹង និងតតាំងជាមួយនឹងភស្តុតាងដែលបានលើកឡើង។ **ខ្ញុំសូមជម្រុញយ៉ាងមុតមាំ ឲ្យក្រសួងយុត្តិធម៌ ពិចារណាតាក់តែងគោលការណ៍ណែនាំស្តីពីលក្ខខណ្ឌតម្រូវនៃការបង្ហាញភស្តុតាង និងធានាថា ចៅក្រមទាំងអស់ទទួលបាននូវការបណ្តុះបណ្តាលអំពីបញ្ហានេះ។ដើម្បីជួយសម្រួលឲ្យមានការយល់ដឹងកាន់តែច្បាស់អំពី សេចក្តីសម្រេចរបស់តុលាការ ខ្ញុំសូមផ្តល់អនុសាសន៍ថា ក្រសួងយុត្តិធម៌ បង្កើនការបណ្តុះបណ្តាល ដែលស្ថិតនៅ ក្រោមរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងតម្រូវឲ្យចៅក្រមទាំងអស់ ធ្វើការផ្សព្វផ្សាយសំអាងហេតុផ្នែកច្បាប់ ដែលបានប្រើប្រាស់នៅក្នុងសំណុំរឿងក្តីនីមួយៗ។**

**ខ្ញុំក៏សូមលើកឡើងនូវអនុសាសន៍របស់ខ្ញុំជាថ្មីម្តងទៀតថា ក្រសួងយុត្តិធម៌ត្រូវធានាថានៅតាមតុលាការនីមួយៗ**

**គួរដាក់បង្ហាញនូវតារាងតម្លៃរឿងក្តីផ្លូវការ ព្រមទាំងតម្លៃស្របច្បាប់ផ្សេងទៀតដែលត្រូវបានកំណត់។** ប្រសិនបើមានភស្តុតាងលេចឡើងពីការយកកម្រៃបន្ថែមដើម្បីសម្រួលរឿងក្តី ការស៊ើបអង្កេតឲ្យមានទណ្ឌកម្មវិន័យត្រូវតែអនុវត្ត។

*ពន្ធនាគារ*

ខ្ញុំបានធ្វើដំណើរទស្សនកិច្ចនៅមណ្ឌលអប់រំកែប្រែទី ១ (ម ១) និង ទី ២ (ម ២) ដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ព្រៃស។ ខ្ញុំសោកស្តាយដែលមិនត្រូវបានអនុញ្ញាតឱ្យជួបបុគ្គលិកអង្គការ Adhoc និងលោក ហុង សុខហួរ ដែលកំពុងត្រូវឃុំខ្លួននៅទីនោះ។ នៅ ម ១ លទ្ធភាពផ្ទុកជនជាប់ឃុំមានចំនួនអតិបរមាប្រមាណ ១៣០០ នាក់ ប៉ុន្តែបច្ចុប្បន្នចំនួនជនជាប់ឃុំនៅទីនោះមានចំនួន ៤៧៣៦ នាក់។ ចំណែកឯនៅ ម ២ វិញ លទ្ធភាពផ្ទុកជនជាប់ឃុំ មានចំនួន ៦០០ ទៅ ៧០០ នាក់ ប៉ុន្តែបច្ចុប្បន្នជនជាប់ឃុំនៅទីនោះមានចំនួន ៩៥៩ នាក់។ កំណើនេះពិតជាជះឥទ្ធិពលដល់លក្ខខណ្ឌឃុំឃាំងនៅក្នុងពន្ធនាគារ។ ខ្ញុំបានកត់សម្គាល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកពន្ធនាគារ និងប្រធានពន្ធនាគារក្នុងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ ឧទាហរណ៍មានដូចជាការផ្ទេរជនជាប់ឃុំ ទៅកាន់ពន្ធនាគារផ្សេងៗ ហើយខ្ញុំក៏ដឹងថាក្រសួងមហាផ្ទៃបានដឹងឮពីបញ្ហាដែលចេះតែកើនឡើងជាលំដាប់នៃចំនួន អ្នកជាប់ឃុំនេះផងដែរ។ នៅពេលដែលកំណែទម្រង់ពន្ធនាគារដ៏ពេញលេញគឺជាជំហានដ៏សំខាន់មួយ កំណែទម្រង់នេះ ពិតជាមិនអាចចៀសផុតពីការពឹងផ្អែកលើពេលវេលាឡើយ។ ជំហានតូចមួយដែលខ្ញុំបានលើកឡើងក្នុងអំឡុងពេល ទស្សនកិច្ចនៅពន្ធនាគារគឺការដាក់បង្ហាញសេចក្តីជូនដំណឹងនៅពីមុខច្រកចូលមណ្ឌលអប់រំកែប្រែនីមួយៗ ដោយគូសបញ្ជាក់មិនឱ្យមានការបង់ប្រាក់ឱ្យទៅអនុរក្ស ឬមន្ត្រីពន្ធនាគារណាម្នាក់ឡើយ ដែលការធ្វើដូចនេះអាចកែលម្អការមក សួរសុខទុក្ខពីសំណាក់ក្រុមគ្រួសាររបស់ជនជាប់ឃុំបាន។ ជាការពិតហើយថាបច្ចុប្បន្នមន្ត្រីអនុរក្សពន្ធនាគារមិនអាចទារ ប្រាក់ពីអ្នកសួរសុខទុក្ខឡើយ ក៏ប៉ុន្តែខ្ញុំធ្លាប់បានដឹងថាក្រុមគ្រួសាររបស់ជនជាប់ឃុំជារឿយៗគិតថា ពួកគេមានកាតព្វកិច្ច ត្រូវបង់ប្រាក់។ **ក្រសួងមហាផ្ទៃគួរចាត់អាទិភាពលើការឆ្លើយតបគ្រប់ជ្រុងជ្រោយ ចំពោះលក្ខខណ្ឌឃុំឃាំងនៅក្នុងពន្ធនាគារ ព្រមទាំងធ្វើការកាត់បន្ថយបញ្ហាផ្សេងៗដែលបណ្តាលមកពីភាពចង្អៀតណែនក្នុងពន្ធនាគារ។ វិធានការរបស់ រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងរបាយការណ៍របស់អនុគណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការទារុណកម្ម (SPT) ទាក់ទងនឹងស្ថានភាពប្រទេសកម្ពុជាគួរតែផ្សព្វផ្សាយជាសាធារណៈ ហើយ របាយការណ៍ក៏គួរផ្សព្វផ្សាយជាសាធារណៈផងដែរ។**

ទន្ទឹមនឹងនេះដែរ ខ្ញុំក៏សូមស្នើឱ្យមានការកាត់បន្ថយការប្រើប្រាស់ជាស្វ័យប្រវត្តិនូវវិធានការឃុំខ្លួនបណ្តោះអាសន្ន ព្រោះវាអាចសម្រាលបញ្ហាខាងលើបាន។ មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាការឃុំខ្លួនបណ្តោះអាសន្ន គួរតែជាករណីពិសេស។ ផ្ទុយទៅវិញ ការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវបានប្រើប្រាស់ធ្វើជាស្តង់ដារស្ទើរគ្រប់ករណី ហើយមូលហេតុសមស្របទាំងឡាយដូចមានចែងក្នុងមាត្រា ២០៥ ក៏កម្រត្រូវបានបង្ហាញឱ្យបានពេញលេញណាស់ បើទោះបីជាមានទម្រង់អនុវត្តសម្រាប់ឱ្យតុលាការប្រើប្រាស់យ៉ាងណាក៏ដោយ។ នៅ ម ១ ខ្ញុំទទួលព័ត៌មានថា ជនជាប់ឃុំបុរសចំនួន ៣២២៤ នាក់ ប៉ុណ្ណោះ គឺជាពិរុទ្ធជន និង ទណ្ឌិ

ត ហើយជនជាប់ឃុំជាបុរសចំនួន ១៥១២ នាក់ ផ្សេងទៀតកំពុងស្ថិតនៅក្នុងស្ថានភាពឃុំខ្លួនបណ្តោះអាសន្ន ឬកំពុងជាប់ក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ (ហើយដូច្នេះមិនត្រូវ បានចាត់ថ្នាក់ជាអ្នកដែលត្រូវបានតុលាការផ្តន្ទាទោសឡើយ)។ ខ្ញុំក៏បានដំណឹងពីក្រសួងយុត្តិធម៌ថា គម្រោងសាកល្បង អនុវត្តទោសជំនួសឱ្យការឃុំខ្លួនកំពុងត្រូវបានអនុវត្តទៅលើបទល្មើសមជ្ឈិមស្រាល (ដែលមានកម្រិតទោសតិចជាង ៦ ខែ)។ យើងលើកទឹកចិត្តឱ្យមានវិធានការនេះ។ ខ្ញុំរីករាយក្នុងការរាយការណ៍ជូនជាដំណឹងថា ក្រសួងយុត្តិធម៌បាន យល់ព្រមបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកនិងអនុវត្តទោសជំនួស និងបង្កើនការលើកទឹកចិត្តការប្រើប្រាស់ទោសជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន។ **ក្រសួងយុត្តិធម៌គួរចាប់ផ្តើមលើកកម្ពស់ការយល់ដឹងនិងការគាំទ្រជាសាធារណៈទៅលើវិធានការផ្សេងៗជំនួសឱ្យការឃុំខ្លួនបណ្តោះអាសន្ន និងការឃុំឃាំងក្នុងពន្ធនាគារ ស្របតាមច្បាប់របស់កម្ពុជា។ គម្រោងសាកល្បងអនុវត្តទោសជំនួសឲ្យការឃុំខ្លួនគួរត្រូវពិនិត្យឡើងវិញ និងគួរត្រូវពិចារណាជាបន្ទាន់ទៅលើការពង្រីក ការអនុវត្តវិធានការនេះឱ្យបានទូលំទូលាយ។**

*ការរៀបចំការបោះឆ្នោត*

ខ្ញុំបានតាមដានការរៀបចំការបោះឆ្នោតឃុំ/សង្កាត់ និងការបោះឆ្នោតជាតិ ដែលនឹងធ្វើនៅពេលដ៏ឆាប់ខាងមុខនេះ។ ខ្ញុំមានសេចក្តីរីករាយដោយកត់សំគាល់ឃើញថា ការចុះឈ្មោះអ្នកបោះឆ្នោត បាននិងកំពុងតែបន្តធ្វើហើយទំនងជាកំពុង ដំណើរការយ៉ាងរលូន។ ចំពោះបុគ្គល ឬក៏ក្រុមណាមួយដែលមានបណ្តឹង អាចដាក់បណ្តឹងនោះដោយផ្ទាល់ទៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីរកដំណោះស្រាយ។ ខ្ញុំនៅតែមានកង្វល់ថា ប្រជាពលរដ្ឋមួយចំនួន ដែលរស់នៅក្នុងប្រទេសកម្ពុជា ពុំទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវនៅឡើយ ដើម្បីអាចឲ្យពួកគេអាច ចុះឈ្មោះបោះឆ្នោតបាន។ តួនាទីរបស់កម្មករចំណាកស្រុកក៏នៅតែពុំទាន់ច្បាស់លាស់នៅឡើយ ប្រហែលជាត្រូវ មានកិច្ចខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដែលមានសិទ្ធិអាចបោះឆ្នោតបាន។ ខ្ញុំមាន កង្វល់ផងដែរថា អគ្គលេខាធិការរងមួយរូបរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បច្ចុប្បន្នកំពុងជាប់ឃុំនៅ ឡើយ និងរង់ចាំសវនាការលើបទចោទប្រកាន់ផ្សេងៗ និងត្រូវបានតុលាការកាត់ទោសលើបទចោទដែលមិនជាប់ ពាក់ព័ន្ធផងដែរ ។ មាត្រា៤ នៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ចែងពាក្យពេចន៍ក្នុងរដ្ឋធម្មនុញ្ញថា "ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់នូវប្រព័ន្ធប្រជាធិបតេយ្យសេរី ពហុបក្ស ។ មាត្រានេះ បានចែងថា ត្រូវតែ មានការបោះឆ្នោតជាទៀតទាត់ និងពិតប្រាកដ ហើយមាត្រានេះក៏បានចែងបន្ថែមទៀតថា សិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ នឹងត្រូវធ្វើឡើងជាសកល និងដោយស្មើភាពគ្នា ។ តម្រូវការក្នុងនីតិវិធីបោះឆ្នោត ទាមទារឲ្យមានឱកាសពេញលេញ និងយុត្តិធម៌ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត។" ខ្ញុំក៏ត្រូវបាន រំលឹកតាមរយៈខ្លឹមសារនៃឧបសម្ព័ន្ធទី៣ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលឆ្លុះបញ្ចាំងនៅក្នុងច្បាប់កម្ពុជាផងដែរថា ជនគ្រប់រូបអាចចូលរួមក្នុងដំណើរការបោះឆ្នោត ហើយសេរីភាពបញ្ចេញមតិ សេរីភាពក្នុងការជួបប្រជុំ និងសេរីភាព ក្នុងការដើរហើរ ត្រូវបានគោរពយ៉ាងពេញលេញដល់គ្រប់គណៈបក្សនយោបាយទាំងអស់ ក្នុងការចូលរួមសំដែងមតិលើ វេទិកានយោបាយដោយស្មើភាពគ្នា។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែបន្តការងារដ៏មានសារសំខាន់ របស់ខ្លួន ដើម្បីធានាឲ្យមានការចុះឈ្មោះបោះឆ្នោតឲ្យបានពេញលេញ។ គ្រប់

បណ្តឹងទាំងអស់ ត្រូវតែបានធ្វើការស៊ើប អង្កេតឲ្យបានឆាប់រហ័ស។ ការអប់រំអ្នកបោះឆ្នោតនឹងអនុញ្ញាតឲ្យអ្នកមានសិទ្ធិបោះឆ្នោតអាចជ្រើសរើស បន្ទាប់ពីទទួល បានព័ត៌មានគ្រប់គ្រាន់ជាមុន។

*ដំណើរវិវឌ្ឍថ្មីៗ*

ខ្ញុំសោកស្តាយ ចំពោះ ការធ្លាក់ចុះនៃស្ថានភាពនយោបាយ ចាប់តាំងពីបេសកកម្មចុងក្រោយរបស់ខ្ញុំនៅក្នុងខែមីនា។ មានការខាតបង់យ៉ាងជ្រាលជ្រៅនៃការជឿទុកចិត្តរវាងគណបក្សនយោបាយធំទាំងពីរ។ **ខ្ញុំសូមជំរុញភាគីទាំងពីរ តាមរយៈអន្តរការីជាការចាំបាច់ដើម្បីស្វែងរកឱកាសសម្រាប់ធ្វើការងារប្រកបដោយផលិតភាពជាមួយគ្នា។ ភាគី ទាំងពីរបានជាប់ឆ្នោតនៅក្នុងឆ្នាំ ២០១៣ ដើម្បីបម្រើប្រជាជនប្រទេសកម្ពុជា។ មនុស្សដែលសមនឹងទទួលបាន ការបោះឆ្នោតឲ្យនេះ គឺជាអ្នកដែលប្រជាជនប្រគល់សិទ្ធិឲ្យបម្រើពួកគេប្រកបដោយវិជ្ជាជីវៈ ដើម្បីឧត្តម ប្រយោជន៍របស់ប្រជាជន។**

សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល អាចជួយរដ្ឋាភិបាលក្នុងការធានាថា ប្រទេសកម្ពុជាគឺជា ប្រទេសមួយដែល ឆ្លើយតបនឹងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ទោះបីជាបំពេញលើសក្តី តាមរយៈការឃ្លាំមើលការរំលោភ សិទ្ធិមនុស្សជាក់ស្តែងនៅហ្នឹងកន្លែង ជួយដល់ជនរងគ្រោះបន្តនីតិវិធីត្រឹមត្រូវតាមច្បាប់ និងនាំយកបញ្ហាសំខាន់ៗ ទាំងនេះឲ្យរដ្ឋាភិបាលបានដឹង។ ចាប់តាំងពីពេលមានតំណាងពិសេស របស់អគ្គលេខាធិការប្រចាំប្រទេសកម្ពុជា ជាលើកដំបូងមក អង្គការសង្គមស៊ីវិលដែលមានលក្ខណៈរស់រវើកបានក្លាយជានិមិត្តរូបនៃសង្គមកម្ពុជាសម័យទំនើប។ រដ្ឋាភិបាលបានចូលរួមជាមួយសង្គមស៊ីវិលក្នុងបញ្ហាជាច្រើន រាប់ទាំង ការតាក់តែងច្បាប់ និងគោលនយោបាយ អនុញ្ញាតឲ្យមានទស្សនៈផ្សេងៗគ្នាជាច្រើនលើការតាក់តែងច្បាប់ និងគោលនយោបាយទាំងនោះ។ កិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីស (មាត្រា៣ និង មាត្រា១៥ នៃកិច្ចព្រមព្រៀងទាក់ទងនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រឹតភាព និងឯកភាពជាតិរបស់ម្ពុជា) ចែងថា ប្រទេសកម្ពុជា សន្យាគាំទ្រ ដល់សិទ្ធិរបស់ពលរដ្ឋកម្ពុជាគ្រប់រូប ដើម្បីអនុវត្តសកម្មភាពដែលលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន។ សង្គមស៊ីវិលក៏មានភារកិច្ចក្នុងការគោរព ច្បាប់ប្រទេសកម្ពុជា និងគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ គ្រាន់តែសកម្មភាពការពារសិទ្ធិមនុស្សមិនគួរចាត់ជារឿងនយោបាយនូវសកម្មភាពបែបនេះឡើយ។ ត្រូវគិតគូរជាពិសេសដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលជាញឹកញយទទួលការគម្រាមគំហែងនិងផលវិបាកបន្ថែមចំពោះសន្តិសុខផ្ទាល់ខ្លួននិងគ្រួសាររបស់ពួកគាត់។ អ្នកការពារសិទ្ធិមនុស្សនិងសកម្មជនសិទ្ធិមនុស្សមិនមែនជាតួអង្គនយោបាយទេ។ រដ្ឋាភិបាលត្រូវគាំទ្រសកម្មភាពទាំងនោះក្នុងបុព្វហេតុលើកស្ទួយនិងគោរពសិទ្ធិមនុស្ស។ ខ្ញុំចូលរួមជាមួយសមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនិងសង្គស៊ីវិលនានាអំពាវនាវអោយមានការសើបអង្កេតឯករាជមិនលំអៀង និងតម្លាភាព លើករណីឃាតកម្មលោកកែម ឡី

អាជ្ញាធរគ្រប់ខេត្តត្រូវតែបានលើកទឹកចិត្តឲ្យអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដោយអនុលោមតាម គោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការអនុវត្តច្បាប់ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

នេះ។ ជាឧទាហរណ៍ ពុំតម្រូវឲ្យមានការអនុញ្ញាតិតាមច្បាប់នោះទេសម្រាប់សកម្មភាពអប់រំ និងការបណ្តុះបណ្តាលឡើយ។ ការធ្វើបាតុកម្មនិងការដង្ហែរក្បួននានាគួរតែត្រូវបានជូនដំណឹងដើម្បីធានាថាអាជ្ញាធរជួយសម្រួលដល់សកម្មភាពនោះ ខណៈដែលធានាឲ្យការរំខានដល់អ្នកដទៃមានកម្រិតតិចតួចបំផុត។ ការសន្មតជាមុននៅក្នុងច្បាប់គឺថា ការដង្ហែរក្បួន និងការធ្វើបាតុកម្មគួរតែប្រព្រឹត្តទៅបាន ដូចដែលបានធ្វើរួចមកហើយកាលពីចុងសប្តាហ៍នេះ ដោយមានការដង្ហែសម្រាប់ គម្រប់ខួបមួយរយថ្ងៃរបស់សពលោក កែម ឡី។ **រដ្ឋាភិបាលត្រូវតែជួយគាំទ្រដល់ប្រជាជនកម្ពុជាគ្រប់រូប ក្នុងការ ធ្វើសកម្មភាពលើកស្ទួយ និងគោរពសិទ្ធិមនុស្ស យ៉ាងហោចណាស់ ក៏តាមរយៈការអនុវត្តច្បាប់ស្តីពី ការធ្វើបាតុកម្មដោយសន្តិវិធីដែរ។ ក្រសួងយុត្តិក៏គួរតែពិចារណាលុបចោល បទល្មើសព្រហ្មទណ្ឌបរិហារកេរ្តិ៍ (មាត្រា ៣០៥-៣០៦) និងការប្រមាថជាសាធារណៈ (មាត្រា ៣០៧) ចេញផងដែរ ដែលជាបទល្មើសដែលកំពុងត្រូវ បានគេយកមកប្រើធ្វើជាសំអាងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស។** ច្បាប់សិទ្ធិមនុស្សអន្តរជាតិតម្រូវថា បទល្មើសទាំងនេះជាបញ្ហារដ្ឋប្បវេណី ប្រសិនជាវាកើតមានឡើង។

*សេចក្តីបញ្ចប់*

នៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បណ្តាគោលការណ៍បង្កើតរដ្ឋធម្មនុញ្ញបច្ចុប្បន្នរបស់កម្ពុជា ត្រូវបានព្រមព្រៀង។ ប្រទេកម្ពុជាថ្មីមួយគឺ លទ្ធិប្រជាធិបតេយ្យសេរី ដោយមានប្រព័ន្ធតុលាការឯករាជ្យ អនុវត្តសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញថ្មី។ ពលរដ្ឋកម្ពុជាគ្រប់រូបត្រូវទទួលការគាំទ្រឲ្យវិលត្រឡប់មករស់នៅក្នុងប្រទេស ខ្លួនវិញ។ អព្យាក្រឹត្យភាពផ្នែកនយោបាយត្រូវតែគោរព ដូចគ្នានេះដែរសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ ត្រូវបានទទួលយកដោយប្រទេសនេះ។ កម្ពុជា ក្នុងឆ្នាំ ២០១៦នេះ គឺខុសគ្នាយ៉ាងខ្លាំងពីប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩១។ ការរីកចម្រើន និងការអភិវឌ្ឍគួរឲ្យសាទរណាស់ ទោះជាយ៉ាងណា ក៏អាចមានទិដ្ឋភាពដែលមិនល្អឥតខ្ចោះ នៃការរីកចម្រើន និងការអភិវឌ្ឍនោះដែរ។ ដល់ពេលវេលាដែលរដ្ឋាភិបាល ត្រូវឈប់ស្តីបន្ទោសបញ្ហានានាដែលកើត មានក្នុងសតវត្សមុន សម្រាប់ស្ថានភាពបច្ចុប្បន្ននេះហើយ។ កម្ពុជាបានទទួលកន្លែងរបស់ខ្លួននៅលើឆាកអន្តរជាតិ ជារដ្ឋអធិបតេយ្យសមភាពមួយហើយដូច្នេះ រដ្ឋាភិបាលត្រូវតែទទួលខុសត្រូវចំពោះការអនុវត្តឲ្យបានពេញលេញ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ/សង្កាត់ នូវសិទ្ធិ និងសេរីភាពទាំងអស់នោះ ដែលមានចែងនៅក្នុងសន្ធិសញ្ញានានា ដែលខ្លួនបានផ្តល់សច្ចាប័នដោយស្ម័គ្រចិត្ត។

ខ្ញុំបានយល់អំពីឆន្ទៈក្នុងចំណោមក្រសួងនានារបស់រាជរដ្ឋាភិបាល ក្នុងការធ្វើការឆ្ពោះទៅរកការធ្វើឲ្យប្រសើរឡើងដល់ ស្ថានភាពសិទ្ធិមនុស្សជាក់ស្តែង។ ហេតុនេះហើយ ខ្ញុំសូមអះអាងជាថ្មីនូវការសន្យារបស់ខ្ញុំក្នុងការជួយជ្រោមជ្រែង តាមរយៈការផ្តល់មតិយោបល់ ការឃ្លាំមើល និងការរាយការណ៍ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

**ចប់**

*លោកស្រី សាស្ត្រាចារ្យ **រ៉ូណា ស្មីត** (ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ តែងតាំងក្នុងខែមីនា ឆ្នាំ២០១៥។ អាណត្តិរបស់អ្នករាយការណ៍ពិសេសនេះ កើតចេញកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយទូលំទូលាយនៃជម្លោះកម្ពុជា។ លោកស្រី ស្មីតគឺជាសាស្ត្រាចារ្យផ្នែកសិទ្ធិមនុស្សអន្តរជាតិនៅចក្រភពអង់គ្លេស។ លោកស្រីបានបង្រៀនច្បាប់សិទ្ធិមនុស្សនៅកម្ពុជាកាលពីពេលកន្លងមក។*

អ្នករាយកាណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។

សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា
http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗសូមទាក់ទងមក៖

**នៅរាជធានីភ្នំពេញ៖** កញ្ញា គ្រីសស្ទីន ភិឃើរីង (Ms. Christine Pickering) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ២៣ ៩៩៣ ៥៩០/៩១ លេខភ្ជាប់បន្ត៖ ២១៣ ឬ អ៊ីម៉ែលcpickering@ohchr.org)
**នៅទីក្រុងហ្សឺណែវ ៖** កញ្ញា ចេននីហ្វឺ ក្រាហ្វត៍ (Ms. Jennifer Kraft) តាមរយៈអ៊ីម៉ែល៖jkraf@ohchr.org ឬ សរសេរមកកាន់ srcambodia@ohchr.org
សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
សាប៉ៀរ សែលាយ៉ា (Xabier Celaya)អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីមែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើបណ្តាញព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក៖**https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖**http://twitter.com/UNrightswire
**ហ្គោហ្គ៊ីល៖Google+៖** https://plus.google.com/+unitednationshumanrights
**យូធូប៖**http://www.youtube.com/UNOHCHR

**ផែនលិបិក្រមសិទ្ធិមនុស្សជាសកល៖** http://uhri.ohchr.org/en